# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៩៤៧/០៨.១១.២០១០

សាលដីកា

លេខ:៥៤ក្រIVអ/០៤.៣.២០១៣

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ: ០៦ក្រ ចុះថ្ងៃទី០៨-២-១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៤.៣.២០១៣ ដែលមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក[redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី[redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ: ៩៤៧ ចុះថ្ងៃទី ០៨.១១.២០១០ រវាង:

-ជនជាប់ចោទ ឈ្មោះ [redacted] ប៊ុនធី ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ មុខរបរឆ្លាក់រូប ទីកន្លែងកំណើតនៅ [redacted] ទីលំនៅបច្ចុប្បន្ននៅ [redacted] ទោសពីមុនគ្មាន ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ[redacted] (រ) នៅលីវ សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី២ថ្មី ។

-ឃាត់ខ្លួនថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៣៩៤ ត.ព្រ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ។

-មេធាវី លោក [redacted]ចន្ថា ការពារសិទ្ធិឲ្យជនជាប់ចោទ ។

-ជាប់ចោទពីបទ: រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅចំណុច ផ្ទះលេខ១២៥ ក្រុម៦ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦.៣.២០១០ តាមបញ្ញត្តិមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] នី ភេទស្រី អាយុ២១ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] មានទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ។

-ជនរងគ្រោះឈ្មោះ [redacted] ឡៃហ៊ាង ភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] មុខរបរនៅផ្ទះ ។

<u>៦រឿងហេតុមានដូចតទៅ</u>

-កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ ជនល្មើសឈ្មោះ [redacted] ប៊ុនធី បានដើរចេញពីផ្ទះរបស់ខ្លួនដោយផ្លោះរបងចូលទៅក្នុងផ្ទះរបស់ជនរងគ្រោះ ឈ្មោះ [redacted] ឡៃហ៊ាង នៅផ្ទះលេខ១២៥ ក្រុម៦ [redacted] រួចស្រែកឲ្យជនរងគ្រោះបើកទ្វារតែជនរងគ្រោះមិនព្រមបើក ជនល្មើសឈ្មោះ [redacted] ប៊ុនធី ក៏ឡើងតាមបង្អួចចូលទៅក្នុងផ្ទះឃើញជនរងគ្រោះកំពុងផ្លាស់សំលៀកបំពាក់ ដោយចងពុងសារុង ជនល្មើសឈ្មោះ [redacted] ប៊ុនធី បានស្ទុះទៅចាប់ជនរងគ្រោះផ្តួល ហើយធ្វើសកម្មភាពរំលោភលើជនរងគ្រោះរហូតបានសំរេច រួចគេចខ្លួនបាត់ ។ លុះដល់ម៉ោង១២:០០នាទី បងប្អូនជនរងគ្រោះបានឃាត់ខ្លួនជនល្មើសយកមកប្រគល់ឲ្យសមត្ថកិច្ច ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ ១០៣ (ក្រ១) ចុះថ្ងៃទី ២២.កញ្ញា.២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅៈ

១.ផ្តន្ទាទោសឈ្មោះ [redacted] ប៊ុនធី ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារត់រូវឲ្យធ្វើការកំណត់រយៈពេល ១៦ឆ្នាំ (ដប់ប្រាំមួយឆ្នាំ) ពីបទៈ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅចំណុចផ្ទះលេខ១២៥ ក្រុម៦ ភូមិសំបូរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២.បង្គាប់ឲ្យឈ្មោះ [redacted] ប៊ុនធី សងប្រាក់ជំងឺចិត្ត ចំនួន ១០.០០០.០០០ (ដប់លាន) រៀលទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នី ការទាមទារលើសពីនេះ ត្រូវច្រានចោល ។

៣.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារដើមបណ្តឹង បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែ៩ ឆ្នាំ២០១២ ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី២១-១១-២០១២ ។

**<u>នាពេលសវនាការៈ</u>**

-ជនជាប់ចោទ ឈ្មោះ [redacted] ប៊ុនធី (វត្តមាន)

-មេធាវីលោក [redacted] ចន្ថា ការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណី [redacted] នី (អវត្តមាន)

-ជនរងគ្រោះឈ្មោះ [redacted] ឡៃហ៊ាង (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍ និងសង្ខេបរឿងជូនអង្គសវនាការ

-ជនជាប់ចោទ ឈ្មោះ [redacted] ប៊ុនធី បានឆ្លើយថាៈ នៅថ្ងៃទី១៦.៣.២០១០ ខ្ញុំបាទ បានឡើងទៅលើផ្ទះជនរងគ្រោះដោយចូលទៅតាមបង្អួចរួចក៏ចាប់ជនរងគ្រោះរំលោភមែន កន្លងមកខ្ញុំបាទធ្លាប់បានរំលោភនាង១០ដងដែរ ។ ខ្ញុំបាទមិនបានទះកំភ្លៀង និងមិនបានគំរាមសំលាប់នាងទេ ។ ថ្ងៃចាប់នាងរំលោភនោះ ពេលរំលោភហើយ គឺមានប្រឡាក់ឈាម ។

-សំណូមពរៈ សុំលោកតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង ។

-តំណាងមហាអយ្យការ ធ្វើសេចក្តីសន្និដ្ឋានៈក្រោយពីបានស្តាប់របាយការណ៍មក និងការសួរដេញដោលមក តាមអង្គហេតុឃើញថាមានការរំលោភសេពសន្ថវៈ ប្រព្រឹត្តឡើងដោយជនជាប់ចោទ [redacted] ប៊ុនធី ទៅលើជនរងគ្រោះ [redacted] ឡៃហ៊ាង រហូតបានសំរេចច្រើនលើក ។ រឿងនេះជនជាប់ចោទបានទទួលសារភាពស៊ីសង្វាក់ជាមួយជនរងគ្រោះ ។ ប៉ុន្តែបើពិនិត្យលើឯកសារពិនិត្យការរំលោភផ្លូវភេទបញ្ជាក់ថា សន្ធៈព្រហ្មចារីនៅល្អ ។ ករណីនេះ សុំក្រុមប្រឹក្សាពិចារណា និងសំរេចតាមច្បាប់ ។

-មេធាវី លោក [redacted] ចន្ថា ធ្វើសេចក្តីសន្និដ្ឋានថាៈក្រោយពីបានស្តាប់របាយការណ៍ និងស្តាប់ការសួរដេញដោលលើជនជាប់ចោទ និងស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការមកឃើញថា កូនក្តីខ្ញុំបានឆ្លើយនៅចំពោះមុខអង្គសវនាការនេះ និងនៅសវនាការសាលាដំបូងបានឆ្លើយសារភាពកំហុសខ្លួនទាំងអស់ បើពិនិត្យលើចម្លើយជនរងគ្រោះថា បានរួមភេទជាមួយគ្នា៣ដងមែន ជនជាប់ចោទថាបានរំលោភនាងចំនួន១០ដង នៅក្នុងឯកសារពិនិត្យការរំលោភផ្លូវភេទបានបញ្ជាក់ថាទ្វារមាសទូលាយធម្មតា សន្ធៈព្រហ្មចារីនៅល្អ ម្យ៉ាងវិញទៀតនៅក្នុងសន្ធៈព្រហ្មចារីរបស់ជនរងគ្រោះពុំមានឃើញមានមេជីវិតរបស់បុរសមាននៅលើនារីរងគ្រោះនោះទេ ។

សំណូមពរៈសុំប្រធានក្រុមប្រឹក្សា និងក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផងដោយផ្អែកតាមមាត្រា១០ និងមាត្រា២៤០ នៃក្រមព្រហ្មទណ្ឌ ។

-ក្រោយពីបានអាន និងស្តាប់ចម្លើយជនជាប់ចោទ ។

-ក្រោយពីបានអានចម្លើយដើមបណ្តឹង ។

-ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន ។

-ក្រោយពីបានស្តាប់មេធាវីធ្វើសេចក្តីសន្និដ្ឋាន ។

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

## សាលាឧទ្ធរណ៍

-យល់ឃើញថា ៖

១.បណ្តឹងឧទ្ធរណ៍លេខ ៧៣២ ចុះថ្ងៃ២១.១០.២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធី ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

-មេធាវី [redacted] ចន្ថា ការពារសិទ្ធិឲ្យជនជាប់ចោទ [redacted] ប៊ុនធី ។

២.ជនជាប់ចោទ [redacted] ប៊ុនធី នៅអធិការដ្ឋាននគរបាលខ័ណ្ឌដង្កោ បានឆ្លើយទទួលស្គាល់ថា កាលពីថ្ងៃ១៦.៣.២០១០ ម៉ោង៨ជាង ខ្លួនបានឡើងចូលតាមបង្អួចផ្ទះជនរងគ្រោះកំពុងស្លៀកសារុងចងពុង ។ ខ្លួនចាប់ផ្តេក រួចហើយរំលោភសេពសន្ថវៈបានសម្រេច ស៊ីសង្វាក់ទៅនឹងចម្លើយឈ្មោះ [redacted] ឡៃហ៊ាង ជាជនរងគ្រោះដែរ ។ ឈ្មោះ [redacted] ឡៃហ៊ាង បានឆ្លើយបញ្ជាក់ថា ពេលឈ្មោះធី ចាប់ខ្លួនស្រែកតែគ្មានអ្នកណាឮ ។ ជនល្មើសបានទះកំភ្លៀងខ្លួន៣ដៃគំរាមកុំឲ្យប្រាប់គេ ។

៣.ដោយសារជាបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ និងដោយសារជនជាប់ចោទសុំបន្ធូរបន្ថយទោស គប្បីក្រុមប្រឹក្សាពិចារណាតាមមាត្រា១០ និងមាត្រា២៤០ នៃក្រមព្រហ្មទណ្ឌវិញ ។

៤.សាលក្រមព្រហ្មទណ្ឌលេខ ១០៣ ក្រ១ ចុះថ្ងៃ២២ កញ្ញា ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវគួរតម្កល់ទុកជាបានការ លើកលែងតែចំណុចផ្តន្ទាទោសឈ្មោះ ជួន ប៊ុនធី ត្រូវកែប្រែតាមការយល់ឃើញខាងលើ ។

## ហេតុដូចនេះ វិនិច្ឆ័យសេចក្តី

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៧៣២ ចុះថ្ងៃ២១.១០.២០១០ របស់ជនជាប់ចោទ ឈ្មោះ [redacted] ប៊ុនធី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០៣ ក្រ១ ចុះថ្ងៃ២២ កញ្ញា ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ លើកលែងតែចំណុចផ្តន្ទាទោស ឈ្មោះ [redacted] ប៊ុនធី ដាក់ពន្ធនាគារ ១៦ឆ្នាំ ត្រូវកែប្រែមកជា១០ឆ្នាំ វិញតាមមាត្រា២៤០ នៃក្រមព្រហ្មទណ្ឌ ។ ចំណុចផ្សេងទៀតតម្កល់ទុកជាបានការដដែល ។

៣.សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងមេធាវី [redacted] ចន្ទា ការពារសិទ្ធិជនជាប់ចោទ ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

សេចក្តីនេះព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់ គ្រប់តំណែង និងកំលាំងប្រដាប់អាវុធ ជួយសហការ អនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរស្របត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រុមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី២៩ ខែតុលា....ឆ្នាំ២០១៥

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]